**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ..៩២១.....សហវ.ប្រក

# ប្រកាស
## ស្ដីពី
## ការបង្កើតក្រុមការងារបច្ចេកទេសរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ សហវ.ប្រក ចុះថ្ងៃទី ខែ ឆ្នាំ២០១៤ ស្ដីពីការបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកានិងកញ្ចប់ថវិកាប្រចាំឆ្នាំ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត ក្រុមការងារបច្ចេកទេសរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងកញ្ចប់ថវិកាប្រចាំឆ្នាំ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ថា **"ក.ប.ផ.ក."** ដើម្បីបំពេញមុខងារជាសេនាធិការបច្ចេកទេស

ជូន ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកានិងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ “ក.ផ.ក.”។

**ប្រការ២.-**

**ក.ប.ផ.ក.** មានសមាសភាពដូចតទៅ÷

| | | | |
|---|---|---|---|
| ១. | អគ្គលេខាធិការ កសហវ | | ប្រធាន |
| ២. | អគ្គលេខាធិការរង កសហវ | មួយចំនួន | អនុប្រធាន |
| ៣. | ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | | អនុប្រធានប្រចាំការ |
| ៤. | តំណាងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | មួយចំនួន | សមាជិក |
| ៥. | តំណាងនាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា | មួយចំនួន | សមាជិក |
| ៦. | មន្ត្រីនៃអគ្គលេខាធិការដ្ឋាន | មួយចំនួន | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **ក.ប.ផ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

**ក.ប.ផ.ក.** មានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- ប្រមូលសរុបផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំដែលរៀបចំដោយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ផ្តល់កិច្ចសម្របសម្រួលនិងការណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងកញ្ចប់ថវិកាប្រចាំឆ្នាំ ដល់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមសារាចររបស់រាជរដ្ឋាភិបាល
- រៀបចំនិងកែលម្អការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការណែនាំរបស់ប្រធាន **ក.ផ.ក.**
- សម្របសម្រួលនិងណែនាំអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទ ក្នុងការរៀបចំអនុកម្មវិធី សកម្មភាព និងសូចនាករ ឱ្យឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ កម្មវិធី និងសូចនាករសមិទ្ធកម្មគន្លឹះដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំនិងប្រមូលសរុបរបាយការណ៍សមិទ្ធកម្ម នៃការអនុវត្តកញ្ចប់ថវិកាប្រចាំឆ្នាំ ដើម្បីលើកសំណើកែលម្អផែនការយុទ្ធសាស្ត្រថវិកា នៃឆ្នាំបន្ទាប់
- បំពេញភារកិច្ចសម្របសម្រួលការងារពាក់ព័ន្ធផ្សេងៗទៀត តាមការណែនាំរបស់ប្រធាន **ក.ផ.ក.**។

**ប្រការ៤.-**

សមាសភាពនៃ **ក.ប.ផ.ក.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវអញ្ជើញនិងដឹកនាំការប្រជុំជំនួស។

**ក.ប.ផ.ក.** មានសិទ្ធិអញ្ជើញមន្ត្រីពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និង ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ